# ចក្ខុវិស័យអភិវឌ្ឍន៍ឧស្សាហកម្មទន្លេមេគង្គ (សេចក្តីព្រាង) ~ដើម្បីក្លាយជាស្នូលនៃបណ្តាញសង្វាក់គុណតម្លៃអាស៊ាន និង ក្រៅតំបន់~

## 1. ស្ថានភាពបច្ចុប្បន្ននៃអនុតំបន់ទន្លេមេគង្គ

- អនុតំបន់ទន្លេមេគង្គមានប្រទេសជាប់ព្រំដែនគ្នាចំនួនប្រាំដែលមានវប្បធម៌ចម្រុះ និងការអភិវឌ្ឍកម្រិតខុសៗគ្នា។ អនុតំបន់ទន្លេមេគង្គបានទទួលការរីកចម្រើនផ្នែកសេដ្ឋកិច្ចប្រកបដោយចីរភាព។ លក្ខណៈអំណោយផលផ្នែកប្រជាសាស្ត្រដែលរួមចំណែកដល់កំណើនការផ្គត់ផ្គង់ពលកម្ម និងកំណើនការប្រើប្រាស់ក្នុងស្រុក។ ទាំងទំនាក់ទំនងរូបវ័ន្ត និងស្ថាប័នមានការរីកចម្រើនដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹង និងកិច្ចខិតខំប្រឹងប្រែងសមាហរណកម្មតំបន់ឆ្ពោះទៅសម្រេចឲ្យបាននូវសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។ ស្ថិតនៅក្នុងបរិបទនេះ អនុតំបន់ទន្លេមេគង្គបានទាក់ទាញវិនិយោគពីបណ្តាប្រទេសផ្សេងៗនៅជុំវិញពិភពលោក ជាទីតាំងមានភាពរីកចម្រើនផ្នែកផលិតកម្ម មូលដ្ឋាននាំចេញ ហើយក៏ជាទីផ្សារអតិថិជនផងដែរ។
    - សមាជិកភាពនៃសភាពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុនដែលមានមូលដ្ឋាននៅក្នុងបណ្តាប្រទេសទន្លេមេគង្គមានកំណើនយ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ2012 មក។ ក្រៅពីឧស្សាហកម្មកម្មន្តសាល ឧស្សាហកម្មសេវាជប៉ុនជាច្រើន រួមទាំងភោជនីយដ្ឋានលក់រាយ និងសេវាដឹកជញ្ជូនកំពុងធ្វើការវិនិយោគនៅក្នុងអនុតំបន់ទន្លេមេគង្គ។ គិតចាប់តាំងពីឆ្នាំ2010មក ការវិនិយោគបរទេស ដែលមានដូចជាការវិនិយោគពីប្រទេសចិន សាធារណរដ្ឋកូរ៉េ និងសហរដ្ឋអាមេរិកក៏មានការកើនឡើងផងដែរ។

➢ ទីតាំងភូមិសាស្ត្ររបស់អនុតំបន់ទន្លេមេគង្គបានផ្តល់អត្ថប្រយោជន៍ដល់ការរីកចម្រើនរបស់ខ្លួនតាមរយៈកំណើនពាណិជ្ជកម្មជាមួយប្រទេសចិន និងប្រទេសឥណ្ឌា (ឧទាហរណ៍ កំណើនពាណិជ្ជកម្មរវាងភាគខាងត្បូងនៃប្រទេសចិន និងប្រទេសវៀតណាម)។

● ពាក់ព័ន្ធនឹងអនុតំបន់ទន្លេមេគង្គជាទីផ្សារតែមួយ ក្រុមហ៊ុនអាជីវកម្មធ្វើការវិភាគយ៉ាងយកចិត្តទុកដាក់ទៅលើចំណុចខ្លាំង និងចំណុចខ្សោយនៃប្រទេសនីមួយៗរួមទាំងគុណភាព និងបរិមាណនៃការផ្គត់ផ្គង់ពលកម្ម សក្តានុពលទីផ្សារ អត្ថិភាពថាមពល និងធនធានធម្មជាតិ ភាពងាយស្រួលនៃហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការតភ្ជាប់ពីក្នុងអនុតំបន់ទន្លេមេគង្គជាមួយនឹងតំបន់ផ្សេងៗទៀត ព្រមទាំងជ្រើសរើសគោលដៅវិនិយោគដែលមានលក្ខណៈសម្បត្តិរួចរាល់សម្រាប់ការពង្រីកសង្វាក់ផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន (ចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រទេសនីមួយៗមានរៀបរាប់លម្អិតនៅក្នុងឯកសារបន្ថែម)។

● ប្រទេសថៃដែលជាចំណុចកណ្តាលនៃអនុតំបន់ទន្លេមេគង្គសំបូរទៅដោយកំណើនឧស្សាហកម្មដែលមានវិស័យគាំទ្រទូលំទូលាយ ដោយតភ្ជាប់នូវសង្វាក់ផ្គត់ផ្គង់ដើមខ្សែ និងចុងខ្សែនូវឧស្សាហកម្មធំៗ មានសហគ្រាសខ្នាតធំ តូច និងមធ្យម។ <u>មាននិន្នាការវិនិយោគ "ប្រទេសថៃបូកមួយ" ដែលចាប់ផ្តើមលេចចេញជារូបរាងដោយមានការលើកកម្ពស់ឧស្សាហកម្មថៃ ការផ្ទេរដំណើរកម្មន្តសាលប្រពលវប្បកម្មពលកម្មទៅបណ្តាលប្រទេសទន្លេមេគង្គជិតខាង</u>។ <u>ស្របគ្នាជាមួយនឹងនិន្នាការ "ប្រទេសចិនបូកមួយ" "ប្រទេសថៃបូកមួយ" កំពុងពន្លឿនការពង្រីកសង្វាក់ផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន និងឧស្សាហាភារូបនីយកម្មចម្បងនៃប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងប្រទេសមីយ៉ាន់ម៉ា</u>។ សង្វាក់ផ្គត់ផ្គង់ឆ្លងកាត់ព្រំដែនទាំងនេះ

កំពុងពង្រីកបន្ថែម និងបានចាប់ផ្តើមភ្ជាប់ជាមួយសង្វាក់ផ្គត់ផ្គង់កំពុងអភិវឌ្ឍន៍នៅក្នុងប្រទេសវៀតណាមភាគខាងជើង កណ្តាល និងខាងត្បូង។

- ក្រុមហ៊ុនអាជីវកម្មមានគោលបំណងប្រើប្រាស់សង្វាក់ផ្គត់ផ្គង់មិនត្រឹមតែនៅទូទាំងអនុតំបន់ទន្លេមេគង្គប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងតំបន់អាស៊ីទាំងមូលផងដែរ ដែលមានដូចជាប្រទេសចិន ប្រទេសឥណ្ឌា និងបណ្តាប្រទេសអាស៊ានផ្សេងៗទៀត។ លំហូរវិនិយោគវិជ្ជមានបច្ចុប្បន្នទៅក្នុងអនុតំបន់ទន្លេមេគង្គមិនអាចធានាថាមាននៅក្នុងទសវត្សរ៍ខាងមុខឡើយ ប៉ុន្តែអាស្រ័យលើការផ្លាស់ប្តូរទៅតាមបរិយាកាស។ ដោយមានការទទួលស្គាល់ច្បាស់លាស់បែបនេះ គោលនយោបាយប្រកបដោយចីរភាពទូទាំងតំបន់ ការធ្វើឯកទេសកម្មនៅក្នុងផ្នែកចំណុចខ្លាំងនីមួយៗ និងការបំពេញលើចំណុចខ្សោយគឺជាចំណុចគន្លឹះនៅក្នុងការសម្រេចបានកំណើនសេដ្ឋកិច្ចបន្ថែមទៀត។
- អនុតំបន់ទន្លេមេគង្គតភ្ជាប់ទីផ្សារធំកំពុងកើតឡើង ប្រទេសចិន ប្រទេសឥណ្ឌា និងបណ្តាប្រទេសអាស៊ានផ្សេងៗទៀត ដែលមានចំនួនប្រជាជនសរុបប្រមាណ 3.3 ពាន់លាននាក់ ដែលជាចំនួនពាក់កណ្តាលនៃប្រជាជនសរុបទូទាំងពិភពលោក។ រចនាសម្ព័ន្ធឧស្សាហកម្មដែលមានលក្ខណៈល្អប្រសើរ គួបផ្សំនឹងទីផ្សារដែលកំពុងរីកចម្រើនទាំងនេះអាចជួយជំរុញអនុតំបន់ទន្លេមេគង្គឲ្យក្លាយទៅជាចំណុចប្រសព្វនៃទីផ្សារធំរបស់អាស៊ីដែលកំពុងកើតឡើង។ កត្តានេះអាចធ្វើឲ្យអនុតំបន់ទន្លេមេគង្គប្រើប្រាស់នូវសក្តានុពលកំណើនសេដ្ឋកិច្ចអាស៊ី តាមរយៈការជួយជំរុញបន្ថែមទៀតនូវកំណើនពាណិជ្ជកម្មអន្តរអាស៊ី បំពេញគម្លាតនៃការអភិវឌ្ឍ និងបង្កើតរចនាសម្ព័ន្ធឧស្សាហកម្មទំនើប។ ដូច្នេះ ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍបន្ថែមគួរមើលឃើញអនុតំបន់ទន្លេមេគង្គជា "ចំណុចស្នូលនៃសង្វាក់គុណតម្លៃអាស៊ី និងពិភពលោក"។

## 2. បញ្ហាប្រឈម និងកាលានុវត្តភាពសម្រាប់អនុតំបន់ទន្លេមេគង្គ

<ចនាសម្ព័ន្ធពាណិជ្ជកម្ម>

- ទំហំពាណិជ្ជកម្មរវាងប្រទេសអនុតំបន់ទន្លេមេគង្គមានការកើនឡើងឥតឈប់ឈរដោយមានការពង្រីក និងការសាយភាយទូទាំងតំបន់នូវទីតាំងផលិតកម្ម ហើយអំណាចទិញក៏កើនឡើងផងដែរ។ ភាគរយនៃពាណិជ្ជកម្មនៅក្នុងតំបន់ទន្លេមេគង្គធៀបនឹងពាណិជ្ជកម្មសរុបមានការកើនឡើងទ្វេដងពី 3% នៅក្នុងឆ្នាំ 2002 រហូតដល់ 6% នៅក្នុងឆ្នាំ 2012។ ទោះជាយ៉ាងនេះក្តី ការពឹងផ្អែកគ្នាទៅវិញទៅមកនៃវិស័យពាណិជ្ជកម្មនៅក្នុងអនុតំបន់ទន្លេមេគង្គនៅតែមានកម្រិតទាបបើប្រៀបធៀបជាមួយការពឹងផ្អែកគ្នាទៅវិញទៅមកនៅក្នុងតំបន់អាស៊ាន ជាពិសេសលើវិស័យម្ហូបអាហារ អេឡិចត្រូនិក និងយានយន្ត។

  បណ្តាញផលិតកម្មឆ្លងកាត់ព្រំដែននៅក្នុងអនុតំបន់ទន្លេមេគង្គនៅតែមានកម្រិតដោយសារតែបរិមាណនៃការផ្ទេរប្លុកផលិតកម្មនៅមានចំនួនតិចតួចនៅឡើយ ដែលបង្ហាញឲ្យឃើញតាមរយៈដំណើរការប្រពលវប្បកម្មពលកម្មខ្លាំងក្លា។ ការអភិវឌ្ឍឧស្សាហកម្មតម្លៃបន្ថែមកាន់តែខ្ពស់ដែលប្រើប្រាស់នូវភាពខ្លាំងរបស់ប្រទេសនីមួយៗ ការបែងចែកពលកម្មឆ្លងកាត់ព្រំដែនកាន់តែស៊ីជម្រៅលើផ្នែកដំណើរការផលិតកម្ម និងភាពពឹងផ្អែកគ្នាទៅវិញទៅមកស៊ីជម្រៅក្នុងវិស័យពាណិជ្ជកម្មគឺមិនទាន់មាននៅឡើយទេ។

- ពាក់ព័ន្ធនឹងពាណិជ្ជកម្មក្រៅតំបន់ អនុតំបន់ទន្លេមេគង្គបានបង្កើនការនាំចេញរបស់ខ្លួនទៅកាន់ទីផ្សារដែលមានការរីកចម្រើនយ៉ាងឆាប់រហ័សដូចជាប្រទេសចិន និងប្រទេសឥណ្ឌានៅក្នុងអត្រាកំណើនប្រចាំជាង 20% ចាប់តាំងពីឆ្នាំ 2000 មក។ តាមរយៈការប្រៀបធៀបបង្ហាញឲ្យឃើញថា ការនាំចេញរបស់ប្រទេសចិនធៀបនឹងប្រទេសឥណ្ឌាមានអត្រាកំណើនប្រចាំឆ្នាំជិត

40% ចំណែកឯភាគរយនៃការនាំចូលពីប្រទេសចិនបានកើនឡើងពីតិចជាង 5% នៃការនាំចូលសរុបរបស់ប្រទេសឥណ្ឌានៅក្នុងឆ្នាំ 2000 រហូត 27% នៅក្នុងឆ្នាំ2009។ កត្តាជំរុញមួយក្នុងចំណោមកត្តាជំរុញធំៗនៃការពង្រីកការនាំចេញរបស់ប្រទេសចិនគឺថា ប្រទេសចិនបានទទួលជោគជ័យនៅក្នុងការបំពេញឧស្សាហកម្មដែលកំពុងមានការរីកចម្រើនរបស់ប្រទេសឥណ្ឌា ដូចជាវិស័យសេវាកម្ម និងវិស័យហេដ្ឋារចនាសម្ព័ន្ធតាមរយៈការផ្គត់ផ្គង់ទំនិញអន្តរកម្ម និងផលិតផលសម្រេចក្នុងតម្លៃប្រកួតប្រជែង (ឧទាហរណ៍ ផលិតផល ICT ដែលមានដូចជា ទូរសព្ទស្មាតហ្វូន និងកុំព្យូទ័រ គ្រឿងបន្លាស់រថយន្តសម្រាប់សេវាជួសជុល និងតំហែទាំ បរិក្ខាររោងចក្រ និងគ្រឿងម៉ាស៊ីនបម្រើឲ្យវិស័យផលិតកម្ម)។ អនុតំបន់ទន្លេមេគង្គក៏នឹងទទួលបានប្រយោជន៍ពីការជំរុញវិស័យឧស្សាហកម្ម និងការអភិវឌ្ឍសង្វាក់ផលិតកម្មជាមួយប្រទេសឥណ្ឌានៅក្នុងលក្ខណៈផ្តល់ផលប្រយោជន៍ និងបំពេញឲ្យគ្នាទៅវិញទៅមកផងដែរ។

- ដើម្បីមានភាពរីកចម្រើនជាមូលដ្ឋាននៃការនាំចេញ បញ្ហាប្រឈមមួយទៀតគឺពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនាំចេញ។ ដោយសារកំពង់ផែសមុទ្រទឹកជ្រៅដែលមានស្រាប់ទាំងអស់នៅក្នុងអនុតំបន់ទន្លេមេគង្គស្ថិតនៅទល់មុខឈូងមហាសមុទ្រប៉ាស៊ីហ្វិក គុណសម្បត្តិនៃទីតាំងភូមិសាស្ត្រនៅជិតឧបទ្វីបឥណ្ឌានៅមិនទាន់បានប្រើប្រាស់ឲ្យអស់សក្តានុពលនៅឡើយទេ។ ដូច្នេះ ការអភិវឌ្ឍកំពង់ផែទឹកជ្រៅនៅក្នុងប្រទសមីយ៉ាន់ម៉ាគឺជាគោលបំណងដ៏សំខាន់មួយ។

<ការវិនិយោគផ្ទាល់ពីបរទេស (FDI)>

- ការវិនិយោគផ្ទាល់ពីបរទេស (FDI) ទៅកាន់អនុតំបន់ទន្លេមេគង្គបាន និងកំពុងមានការកើន

ឡើងយ៉ាងឆាប់រហ័សពី 4 ពាន់លានដុល្លារនៅដើមឆ្នាំ 2000 រហូតដល់ 10 ពាន់លានដុល្លារនៅក្នុងទសវត្សរ៍ឆ្នាំ 2010។ ដោយមានកត្តាជំរុញពីកំណើនសេដ្ឋកិច្ចដោយសារលក្ខណៈអំណោយផលផ្នែកប្រជាសាស្ត្រ និងហេដ្ឋរចនាសម្ព័ន្ធទំនើប អនុតំបន់នេះបានប្រែក្លាយទៅជាគោលដៅ FDI របស់ពិភពលោក។

- ទោះជាយ៉ាងនេះក្តី ចាំបាច់ត្រូវមានការត្រួតពិនិត្យឲ្យបានល្អិតល្អន់ថាតើ FDI នឹងនាំមកនូវភាពរីកចម្រើនដល់វិស័យឧស្សាហកម្មនៅក្នុងអនុតំបន់នៅក្នុងរយៈពេលវែងដែរឬទេ។ នាពេលបច្ចុប្បន្ននេះ FDI ទៅកាន់អនុតំបន់ទន្លេមេគង្គគឺផ្តោតសំខាន់ទៅលើធនធានធម្មជាតិ (ឧទាហរណ៍ ប្រេង និងឧស្ម័ន ទឹក និងដីធ្លី) ឧស្សាហកម្មប្រពលវប្បកម្មពលកម្មដែលប្រើប្រាស់ថ្លៃដើមពលកម្មទាប (ដូចជា កាត់ ផលិត និងតម្រឹម (CMT) នូវផលិតផលស្បែកជើង និងសម្លៀកបំពាក់) និងខ្សែសង្វាក់ដំឡើងទ្រង់ទ្រាយធំនៃឧស្សាហកម្មកម្មន្តសាល។ FDI ពីប្រទេសជប៉ុនមានលក្ខណៈ ជាការវិនិយោគទាំងដោយក្រុមហ៊ុនខ្នាតធំ និងខ្នាតតូចពីខ្សែខាងលើទៅខ្សែខាងក្រោមនៃសង្វាក់ គុណតម្លៃកម្មន្តសាលពិសេសនៅទូទាំងអនុតំបន់ទន្លេមេគង្គ។ កត្តានេះគឺ ដោយសារតែក្រុមហ៊ុនជប៉ុនសំឡឹងឃើញអនុតំបន់ទន្លេមេគង្គជាមូលដ្ឋានផលិតកម្មតែមួយគត់ និងចង់កសាងបណ្តុំឧស្សាហកម្មទូទាំងតំបន់ទន្លេមេគង្គដោយពង្រីកសង្វាក់គុណតម្លៃមានស្រាប់របស់ខ្លួននៅក្នុងប្រទេសថៃ និងប្រទេសចិន អនុវត្តតាមការអភិវឌ្ឍរបស់ប្រទេសជិតខាង។ ជាងនេះទៅទៀត ដោយបោះជំហានជាមួយនឹងការអភិវឌ្ឍឧស្សាហកម្មកម្មន្តសាល និងកំណើនប្រាក់ចំណូលក្នុងស្រុក ការវិនិយោគកំពុងរីកដុះដាលទៅជាឧស្សាហកម្មផ្សេងៗ មានចាប់ពីអាជីវកម្មលក់ដុំ និងលក់រាយរហូតដល់សេវាពាក់ព័ន្ធនឹងកម្មន្តសាល។
- ដោយកំណត់គោលដៅអភិវឌ្ឍរយៈពេលមធ្យមទៅរយៈពេលវែងជាការផ្លាស់ប្តូរឆ្ពោះទៅ

រចនាសម្ព័ន្ធឧស្សាហកម្មទំនើប គួរលើកកម្ពស់ដល់ការបង្កើតបណ្តុំឧស្សាហកម្មផ្សេងៗជាច្រើនដែលដឹកនាំ ដោយឧស្សាហកម្មខ្នាតតូច និងមធ្យមដែលគាំទ្រដល់ឧស្សាហកម្មគុណតម្លៃបន្ថែមខ្ពស់ (ឧទាហរណ៍ ឧស្សាហកម្មគាំទ្ររួមទាំងការផលិត គ្រឿងបន្លាស់/ផលិតផលពាក់កណ្តាលសម្រេច ឧស្សាហកម្មរចនា ICT អាជីវកម្មលក់រាយ និងឧស្សាហកម្មសេវាផ្សេងៗទៀត) គួរត្រូវបានលើកកម្ពស់ផងដែរ។ បន្ទាប់មកទៀត ការកែច្នៃធនធានធម្មជាតិដោយមិនគ្រាន់តែនាំចេញវត្ថុធាតុដើមគ្មានការកែច្នៃគួរជួយជំរុញដល់ឧស្សាហកម្មគុណតម្លៃបន្ថែម។

<កិច្ចសហការអាជីវកម្មក្នុងស្រុក>

- នៅក្នុងពេលដែលសេដ្ឋកិច្ចរបស់អនុតំបន់ទន្លេមេគង្គមានការកើនឡើង ក្រុមហ៊ុនអាជីវកម្មក្នុងស្រុកក៏មានការកើនឡើងគួរឲ្យកត់សម្គាល់ផងដែរ។ ស្ថានភាពនេះកើតមានជាពិសេសនៅក្នុងប្រទេសថៃ ដែលមានក្រុមហ៊ុនអាជីវកម្មចំនួន11នៅក្នុងចំណោមក្រុមហ៊ុនអាស៊ានកំពូលទាំង50 តាមរយៈមូលធនភាគរូបនីយកម្មទីផ្សារ និងជាប់ចំណាត់ថ្នាក់លេខ 3 បន្ទាប់ពីប្រទេសសិង្ហបុរី និងម៉ាឡេស៊ី។

  លើសពីនេះទៅទៀត នៅក្នុងករណីប្រទេសថៃ គឺមិនត្រឹមតែទទួលយកការវិនិយោគចូលក្នុងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែក៏ដើរតួនាទីសំខាន់នៅក្នុងការផ្តល់ការវិនិយោគចេញក្រៅប្រទេសចូលក្នុងបណ្តាប្រទេសទន្លេមេគង្គផងដែរ។ ជាលទ្ធផល នៅត្រឹមឆ្នាំ2012 ប្រទេសថៃបានក្លាយជា អ្នកផ្តល់សុទ្ធសាធនូវ FDI។ កិច្ចសហការអាជីវកម្មឆ្លងកាត់ព្រំដែននៅក្នុងអនុតំបន់មានការកើនឡើងជាបណ្តើរៗ ដែលនាំមុខដោយក្រុមហ៊ុនអាជីវកម្មប្រទេសថៃ។ ឧទាហរណ៍

ជាក់ស្តែង គឺការទទួលបានទឹកប្រាក់ចំនួន 235 លានដុល្លារអាមេរិករបស់ក្រុមហ៊ុន Prime Group of Vietnam ដោយក្រុមហ៊ុន Siam Cement Group របស់ប្រទេសថៃនៅក្នុងឆ្នាំ2013។ កិច្ចសហការ អាជីវកម្មឆ្លងកាត់ព្រំដែននៅក្នុងវិស័យហិរញ្ញវត្ថុក៏កំពុងមានការនាំមុខកាន់តែខ្លាំងផងដែរ។ ឧទាហរណ៍មួយគឺ ករណីក្រុមហ៊ុន Mitsubishi UFJ Bank ទិញធនាគារ Bank of Ayudhya នៅក្នុងឆ្នាំ2013។ ឧទាហរណ៍មួយទៀតគឺការពង្រីកអាជីវកម្មរបស់ធនាគារពាណិជ្ជកម្មថៃទៅក្នុងប្រទេសតំបន់ទន្លេមេគង្គផ្សេងទៀតជាការឆ្លើយតបចំពោះនិន្នាការ "ប្រទេសថៃបូកមួយ"។ កិច្ចសហការអាជីវកម្មទូទាំងតំបន់ទន្លេមេគង្គកំពុងត្រូវបានពន្លឿនផងដែរ។

- ទោះជាយ៉ាងនេះក្តី មានឱកាសដែលមិនទាន់ប្រើប្រាស់សម្រាប់កិច្ចសហការអាជីវកម្មឆ្លងដែនជាពិសេសនៅពេលប្រៀបធៀបជាមួយគំរូកិច្ចសហការអាជីវកម្មទូលំទូលាយជាងនៅក្នុងតំបន់ជិតខាង។ ក្រុមហ៊ុនអាជីវកម្មបរទេសមានបំណងស្វែងរកដៃគូអាជីវកម្មក្នុងស្រុកដើម្បីអភិវឌ្ឍអាជីវកម្ម និងផ្តល់ធនធានក្នុងស្រុក។ ទោះបីជាយ៉ាងណា ក្រុមហ៊ុនទាំងនោះប្រឈមនឹងការលំបាកជាច្រើនគឺដោយសារពុំមានអាជីវកម្មគ្រប់គ្រាន់ និងភាពប្រកួតប្រជែងរបស់អាជីវកម្មក្នុងស្រុកនៅក្នុងតំបន់។
- វត្តមានអាជីវកម្មរបស់សហគ្រាសទន្លេមេគង្គ ជាពិសេសសហគ្រាសប្រទេសថៃ មានកម្រិតខ្ពស់នៅក្នុងតំបន់អាស៊ាន ប៉ុន្តែនៅតែមានកម្រិតទាបបើប្រៀបធៀបជាមួយវត្តមានអាជីវកម្មរបស់សហគ្រាសចិន និងឥណ្ឌានៅក្នុងតំបន់អាស៊ី។ មានឱកាសកែលម្អលើផ្នែកបទប្បញ្ញត្តិ ឬគោលនយោបាយពាក់ព័ន្ធនឹងការជំរុញកិច្ចសហការអាជីវកម្ម រួមទាំងសម្ព័ន្ធអាជីវកម្ម ឬ M&A។ សហគ្រាសទន្លេមេគង្គអាចស្វែងរកឱកាសវិនិយោគទៅកាន់ប្រទេសជប៉ុនដើម្បី

លើកកម្ពស់ភាពប្រកួតប្រជែង និងអភិបាលកិច្ចសាជីវកម្មរបស់ខ្លួនដែលអាចទទួលបានពីចំណេះដឹងរបស់សហគ្រាសជប៉ុន។

<សកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D)>

- តាមរយការទាក់ទាញវិនិយោគបរទេសពីក្រុមហ៊ុនអាជីវកម្មដែលមានបច្ចេកវិទ្យាទំនើប និងជំរុញដល់ឧស្សាហកម្មគាំទ្រ បណ្ដុំឧស្សាហកម្មកម្រិតពិភពលោកដែលមានឧស្សាហកម្មផ្អែកលើចំណេះដឹងដូចជាយានយន្ត និងអេឡិចត្រូនិកបានចាប់ផ្ដើមបង្កើតនៅក្នុងអនុតំបន់ទន្លេមេគង្គ។

  ជាងនេះទៅទៀត មូលដ្ឋានផលិតកម្មនៅក្នុងប្រទេសថៃមានការអភិវឌ្ឍនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ឧស្សាហកម្មយានយន្ត និងគ្រឿងបន្លាស់ធំៗរបស់ប្រទេសជប៉ុន (ដូចជា សម្បកកង់រថយន្ត និងថ្មពិល) គាំទ្រដល់ការអភិវឌ្ឍទាំងនេះតាមរយៈការប្រកាសអំពីប្រពលភាពរបស់ខ្លួននៅក្នុងការពង្រីកមុខងារ R&D នៅក្នុងអនុតំបន់ ជាពិសេសក្នុងប្រទេសថៃ។

  ទោះជាយ៉ាងនេះក្ដី នៅពេលប្រៀបធៀបជាមួយប្រទេសចិន ប្រទេសសិង្ហបុរី និងប្រទេសម៉ាឡេស៊ីតាមសមាមាត្រចំនួនប្រជាជន ចំនួនអ្នកស្រាវជ្រាវ និងការអនុវត្ត PCT (សន្ធិសញ្ញាសហប្រតិបត្តិការស្ដីពីប៉ាតង់) មានកម្រិតទាបខ្លាំងទោះជាបីនៅក្នុងប្រទេសថៃ និងប្រទេសវៀតណាម ដែលមានសក្ដានុពលខ្លាំងជាងក្នុងការក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្មប្រពលវប្បកម្មចំណេះដឹង។ សកម្មភាព R&D គួរមានការស្រាវជ្រាវបន្ថែមទៀតដើម្បីពង្រឹងមូលដ្ឋានគ្រឹះបច្ចេកវិទ្យារបស់ខ្លួន។

<លក្ខណៈប្រកួតប្រជែងនៅក្នុងវិស័យសហគ្រាសខ្នាតតូច និងមធ្យម (SME)>

- ដោយសារ SME មានចំណែកយ៉ាងធំនៅក្នុងរចនាសម្ព័ន្ធឧស្សាហកម្មជាតិពីសកម្មភាព

សាជីវកម្ម និងចក្ខុវិស័យការងារ ទើបការជួយជំរុញដល់ SME គួរតែមានសារសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិ។ ទោបីយ៉ាងណា ដោយសារធនធានមនុស្ស និងធនធានហិរញ្ញវត្ថុនៅមានកម្រិត ទើប SME នៅក្នុងតំបន់មេគង្គកំពុងប្រឈមមុខនឹងផលវិបាកនៅក្នុងបង្កើនផលិតភាពដោយសារកង្វះការច្នៃប្រឌិត និងការបើកនូវទីផ្សារថ្មីៗ។

- ដើម្បីជំរុញ SME ដែលមានលក្ខណៈប្រកួតប្រជែង ការលុបបំបាត់បញ្ហារាំងស្ទះផ្នែកធនធានហិរញ្ញវត្ថុ និងធនធានមនុស្សគួរត្រូវបានចាត់ទុកជាអាទិភាពចម្បង តាមរយៈការលើកកម្ពស់សហគ្រិនភាព ការចូលរួមពលកម្មរបស់ស្ត្រី និងយុវជន ការទទួលបានហិរញ្ញវត្ថុបែបប្រពៃណី និងមិនប្រពៃណី។ ក្រៅពីនេះគឺចាំបាច់ត្រូវសម្រេចឲ្យបាននូវការលើកកម្ពស់ផលិតភាព និងការកែលម្អលទ្ធភាពចូលទៅក្នុងទីផ្សារដោយចូលរួមនៅក្នុងសង្វាក់ផ្គត់ផ្គង់សកល និងបណ្តុំឧស្សាហកម្មដែលបង្កើតឡើងដោយ MNC និងត្រូវលើកកម្ពស់ការច្នៃប្រឌិត។ ជាពិសេសដោយសារព័ត៌មានស៊ីមេទ្រី និងបញ្ហាសេដ្ឋកិច្ចមាត្រដ្ឋាន SME មាននិន្នាការប្រឈមនឹងផលវិបាកនៅក្នុងការទទួលបានហិរញ្ញវត្ថុជាងក្រុមហ៊ុនធំៗ។ ការលើកកម្ពស់លទ្ធភាពទទួលបានហិញ្ញវត្ថុនៅក្នុងវិស័យ SME គឺជាបញ្ហាដែលត្រូវដោះស្រាយបន្ទាន់។
- ដោយពិចារណាទៅលើសង្វាក់ផ្គត់ផ្គង់សកលដែលបានបង្កើតឡើងនៅទូទាំងប្រទេសទន្លេមេគង្គ គំនិតផ្តួចផ្តើមដែលគាំទ្រដោយរដ្ឋាភិបាល រួមទាំងគោលនយោបាយ និងបទប្បញ្ញត្តិដែលមានការសម្របសម្រួលនៅទូទាំងប្រទេស និងការធ្វើឲ្យមានលក្ខណៈងាយស្រួលនូវនីតិវិធីផ្សេងៗរបស់រដ្ឋាភិបាលមានសារសំខាន់នៅក្នុងការដោះស្រាយបញ្ហាខាងលើឲ្យមានប្រសិទ្ធភាព។

<បណ្តាញតភ្ជាប់នៅក្នុងតំបន់>

- ក្នុងពេលថ្មីៗនេះ មានការកែលម្អជាប្រចាំនូវបណ្តាញតភ្ជាប់នៅក្នុងតំបន់មេគង្គ។ ឧទាហរណ៍ជាក់ស្តែងគឺការកែលម្អនៅច្រកសេដ្ឋកិច្ចខាងត្បូង រួមទាំងការបើកស្ពាន Tsubasa ដែលរដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយឥតសំណង ODA របស់ខ្លួន ដែលបានកសាងផ្លូវនាំចេញរហ័សសម្រាប់ផលិតផលកម្ពុជា ដោយតភ្ជាប់តំបន់ដីគោកជាមួយស្ថានីយអន្តរជាតិ CaiMep។ ទោះជាយ៉ាងនេះក្តី បញ្ហាហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងផ្នែកទន់ពាក់ព័ន្ធនឹងបណ្តាញតភ្ជាប់នៅតែជាបញ្ហារាំងស្ទះចម្បងសម្រាប់ការសម្របសម្រួលការអភិវឌ្ឍសង្វាក់ផ្គត់ផ្គង់ទូទាំងតំបន់។ ជាពិសេស ក្រុមហ៊ុនអាជីវកម្មអះអាងថា មានការរីកចម្រើនតិចតួចលើការអភិវឌ្ឍផ្លូវថ្នល់នៅក្នុងប្រទេសមីយ៉ាន់ម៉ាជាមួយនឹងបណ្តាប្រទេសនៅជុំវិញ បើប្រៀបធៀបជាមួយការរីកចម្រើនឥតឈប់ឈរ នៅក្នុងផ្នែកផ្សេងៗទៀតនៃអនុតំបន់ទន្លេមេគង្គ។ នៅក្នុងយុទ្ធសាស្ត្រ Tokyo ឆ្នាំ2015 ដែល អនុម័តដោយមេដឹកនាំប្រទេសជប៉ុន និងបណ្តាប្រទេសទន្លេមេគង្គនៅថ្ងៃទី04 ខែកក្កដា ឆ្នាំ2015 ប្រទេសជប៉ុនបានសន្យាផ្តល់ទឹកប្រាក់ប្រហែល 750 ពាន់លានយន់ជាជំនួយអភិវឌ្ឍ ផ្លូវការដល់តំបន់ទន្លេមេគង្គសម្រាប់រយៈពេលបីឆ្នាំបន្ទាប់ (2016-2018) ដោយមានគោលបំណងធានាស្ថិរភាពតំបន់ និងសម្រេចឲ្យបាននូវ "គុណភាពកំណើន" នៅក្នុងតំបន់ទន្លេមេគង្គ។ ក្រៅពីនោះ នៅក្នុងយុទ្ធសាស្ត្រតូក្យូថ្មី បណ្តាប្រទេសទន្លេមេគង្គបានបង្ហាញអំពីគោលបំណងគាំទ្រដល់គំនិតផ្តួចផ្តើមរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងការពង្រីកសមត្ថភាពផ្តល់ប្រាក់កម្ចីរបស់ខ្លួន និងបានស្វាគមន៍ការពិចារណារបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងការបង្កើនមូលធនអនាគតរបស់ខ្លួន ព្រមទាំងសេចក្តីប្រកាសរបស់ប្រទេសជប៉ុនអំពី "ភាពជាដៃគូសម្រាប់ហេដ្ឋរចនាសម្ព័ន្ធប្រកបដោយគុណភាព" ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងតាមរយៈការពិចារណាលើយន្តការ

សហប្រតិបត្តិការថ្មីរវាងអង្គការ JICA ធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីសម្របសម្រួលការប្រើប្រាស់ PPP សម្រាប់ការវិនិយោគហេដ្ឋា រចនាសម្ព័ន្ធ។ តាមរយៈការប្រើប្រាស់គំនិតផ្តួចផ្តើមទាំងនេះ មានការរំពឹងទុកថា បណ្តាញ តភ្ជាប់តំបន់ទន្លេមេគង្គនឹងត្រូវពង្រឹងបន្ថែមទៀត។ ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ ត្រូវលើកទឹកចិត្តឲ្យមានការបង្កើតជាចាំបាច់នូវបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូន និងការអនុវត្ត ដូចៗគ្នាដើម្បីធានាការសម្របសម្រួល និងតម្លាភាពនៃប្រព័ន្ធដឹកជញ្ជូនក្នុងតំបន់។

- <u>ជាពិសេសនៅក្នុងការដឹកជញ្ជូន ការធ្វើទំនើបកម្មតាមរយៈសេវាកាន់តែមានលក្ខណៈទំនើប និងចម្រុះនឹងក្លាយជាកត្តាសំខាន់សម្រាប់កាត់បន្ថយថ្លៃចំណាយលើការដឹកជញ្ជូន។</u>

កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមមានការដាក់ឲ្យប្រើប្រាស់ និងដំណើរការប្រកបដោយចីរភាពនូវប្រព័ន្ធសញ្ញាប័ណ្ណ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់សេវាទំនិញរួមបញ្ចូល ព្រមទាំងសង្វាក់រក្សាភាពត្រជាក់។ ដូចគ្នានេះដែរ ការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែនក្រៅផ្លូវការគួររៀបចំជាបទប្បញ្ញត្តិឲ្យបានសមស្របដើម្បីអភិវឌ្ឍសេវាដឹកជញ្ជូនឆ្លងកាត់ព្រំដែនទំនើប។

ជាមួយគ្នានេះដែរ ការពង្រឹងជាប្រចាំនូវច្បាប់ចរាចរណ៍មានស្រាប់ (ឧទាហរណ៍ បទប្បញ្ញត្តិស្តីពីទម្ងន់បន្ទុកទំនិញ) គួរពង្រឹងបន្ថែមទៀតដើម្បីធានាអាយុកាលប្រើប្រាស់ផ្លូវថ្នល់យូរអង្វែង និងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗទៀតនៅកម្រិតប្រើប្រាស់ឧស្សាហកម្ម ហើយហេដ្ឋារចនាសម្ព័ន្ធរូបវន្តគួរត្រូវបានទទួលស្គាល់ និងថែទាំជា "កម្មសិទ្ធិរួម" របស់បណ្តាប្រទេសទន្លេមេគង្គទាំងអស់។

- <u>កិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA) និងអនុស្សារណៈនៃការយោគយល់ទ្វេភាគី និងត្រីភាគីពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនេះមិនបានរួមចំណែកធំដុំនៅក្នុងការដឹកជញ្ជូនក្នុងតំបន់ឡើយ។</u> បណ្តាលប្រទេសទន្លេមេគង្គចាំបាច់ត្រូវអនុវត្ត CBTA

ដែលកាន់តែមានលក្ខណៈជាកម្មវិធីជាងមុន។ គួរពិចារណាលើការដាក់ឲ្យប្រើប្រាស់ឆាប់រហ័សនូវយន្តការអធិការកិច្ចច្រកតែមួយ (SWI) ព្រមទាំងការដាក់ឲ្យប្រើប្រាស់នូវអធិការកិច្ចច្រកចេញចូលតែមួយ (SSI) នៅតំបន់គ្រប់គ្រងទូទៅ (CCA) នៅច្រកព្រំដែនធំៗ។ ជាមួយគ្នានេះដែរ ប្រតិបត្តិការត្រឹមត្រូវស្របទៅទាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទាំងនេះ ព្រមទាំងការផ្សព្វផ្សាយជូនសាធារណជននូវព័ត៌មានអំពីបទប្បញ្ញត្តិថ្មីៗ និងប្រតិបត្តិការពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងគួរត្រូវបានធានា។ ជាងនេះទៅទៀត នៅក្នុងអនុស្សារណៈនៃការយោគយល់មួយចំនួន ការបង្កើនអាជ្ញាប័ណ្ណឆ្លងកាត់ព្រំដែនគួរពិចារណាដោយមានភាពបត់បែនដើម្បីឆ្លើយតបទៅនឹងតម្រូវការអាជីវកម្មទៅលើទំនិញ។

<ការផ្គត់ផ្គង់ថាមពល និងបរិស្ថាន>

- បញ្ហាប្រឈមមួយទៀតគឺកង្វះស្ថិរភាពនៅក្នុងផ្គត់ផ្គង់អគ្គិសនីនៅក្នុងអនុតំបន់ទន្លេមេគង្គ។ ពុំមានការវិនិយោគច្រើនដែលសំដៅលើការបង្កើនស្ថិរភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ថាមពលក្នុងតំបន់តាមរយៈការអភិវឌ្ឍក្រឡាចក្រត្រង្គថាមពលក្នុងតំបន់ឡើយ។ គួរធ្វើការអភិវឌ្ឍលក្ខណៈ ចម្រុះនៃថាមពលប្រសើរបំផុតដោយពិរចារណាលើការពិតដែលថាការផ្គត់ផ្គង់ ថាមពលមានស្រាប់គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើការផលិតថាមពលវារីអគ្គិសនី ហើយចាំបាច់ត្រូវមានការបំពេញបន្ថែមនៅរដូវប្រាំង។ ក្នុងចំណោមប្រទេសទាំង5នៅក្នុងតំបន់មានតែ ប្រទេសថៃមួយគត់ដែលមានភាពល្បីល្បាញជាងប្រទេសចិនលើការថែរក្សាស្ថិរភាពផ្គត់ផ្គង់ អគ្គិសនីឲ្យនៅកម្រិតមូលដ្ឋាននៃផលិតកម្ម។ ថ្លៃឯកតាអគ្គិសនីក្នុងប្រទេសកម្ពុជាគឺខ្ពស់ជាងប្រទេសចិន ខណៈដែលថ្លៃអគ្គិសនីបានចាប់ផ្តើមកើនឡើងនៅក្នុងប្រទេសវៀតណាម និងប្រទេសមីយ៉ាន់ម៉ា។

- ក្រុមហ៊ុនជប៉ុនបានចូលរួមនៅក្នុងគម្រោងផលិតថាមពលក្នុងប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ មីយ៉ាន់ម៉ា ប្រទេសថៃ និងប្រទេសវៀតណាម។ នៅក្នុងប្រទេសដែលការផលិតថាមពលអគ្គិសនីត្រូវបានធ្វើកំណែទម្រង់ ក្រុមហ៊ុនផ្គត់ផ្គង់ថាមពលឯករាជ្យ (IPP) មានទំនោរសាងសង់រោងចក្រថាមពលតូច និងមិនគ្រប់គ្រាន់។
- ដោយរំពឹងថាការប្រើប្រាស់អគ្គិសនីនឹងកាន់តែមានការកើនឡើងស្របពេលមានកំណើនសេដ្ឋកិច្ចនៅក្នុងអនុតំបន់ទន្លេមេគង្គ មានភាពតម្រូវការបន្ទាន់លើផ្នែកហេដ្ឋារចនាសម្ព័ន្ធថាមពល និងការផ្លាស់ប្តូរថាមពលអគ្គិសនីក្នុងតំបន់។ ក្រៅពីនេះ ការអភិវឌ្ឍប្រេង និងឧស្ម័នគួរលើកកម្ពស់បន្ថែមទៀតដើម្បីដោះស្រាយបញ្ហាតម្រូវការថាមពលអគ្គិសនីដែលរំពឹងថានឹងមានការកើនឡើង ដោយយកចិត្តទុកដាក់ខ្ពស់ចំពោះផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ។
- ប្រសិទ្ធផល និងការអភិរក្សថាមពល (EE&C) ក៏ចាំបាច់ត្រូវធ្វើការលើកកម្ពស់ដើម្បីបញ្ចៀសការកើនឡើនឆាប់រហ័សនូវតម្រូវការថាមពល។ ការបង្កើតគោលនយោបាយ និងក្របខណ្ឌច្បាប់ EE&C មានសារសំខាន់ជាពិសេសសម្រាប់ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងប្រទេសមីយ៉ាន់ម៉ា។
- ស្របគ្នាជាមួយកំណើនសេដ្ឋកិច្ច និងកំណើនតម្រូវការថាមពលអគ្គិសនីនៅក្នុងអនុតំបន់ទន្លេមេគង្គ បញ្ហាប្រឈមបរិស្ថានផ្សេងៗបានកើតឡើង ដែលមានដូចជា ការបំពុលខ្យល់/ទឹក ការកាប់បំផ្លាញព្រៃឈើ ការហូរច្រោះដី កង្វះខាតទឹក និងបញ្ហាកាកសំណល់គ្រោះថ្នាក់ផ្សេងៗទៀត។
- រដ្ឋាភិបាលជប៉ុនបានប្រឈមនឹងបញ្ហាស្រដៀងគ្នានេះដែរនៅក្នុងពេលប្រទេសរបស់ខ្លួនមានកំណើនសេដ្ឋកិច្ចខ្ពស់ និងបានបង្កើតវិធានការកាត់បន្ថយជាច្រើនចាប់តាំងពីការរៀបចំបទប្បញ្ញត្តិ និងចក្ខុវិស័យបច្ចេកវិទ្យា។ ការសម្របសម្រួលរវាងបណ្តាប្រទេសទន្លេមេគង្គ

និងប្រទេសជប៉ុនក្នុងតំបន់នេះនឹងត្រូវអនុវត្តតាមរយៈការផ្តល់ចំណេះដឹង និងបច្ចេកវិទ្យាដែលរដ្ឋាភិបាលជប៉ុនបាន និងកំពុងធ្វើការបង្កើន។

<ការអភិវឌ្ឍធនធានមនុស្ស (HRD)>

- ទោះបីជានៅក្នុងពេលថ្មីៗនេះប្រាក់បៀវត្សរ៍កម្មករ និងប្រធានគ្រប់គ្រងនៅក្នុងប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ប្រទេសមីយ៉ាន់ម៉ា និងប្រទេសវៀតណាម មានការកើនឡើងក៏ដោយ ក៏ថ្លៃចំណាយលើប្រាក់បៀវត្សរ៍នៅតែមានលក្ខណៈប្រកួតប្រជែង បើប្រៀបធៀបជាមួយ ប្រទេសចិន ឥណ្ឌា និងបណ្តាប្រទេសអាស៊ានផ្សេងៗទៀត។
- ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនអាជីវកម្មព្រមានថា ប្រាក់ឈ្នួលកើនឡើងដោយគ្មានកំណើនផលិតភាព អត្រាឈប់របស់បុគ្គលិកខ្ពស់ និងជម្លោះការងារកើតឡើងញឹកញាប់អាចកាត់បន្ថយភាពទាក់ទាញរបស់អនុតំបន់ទន្លេមេគង្គជាមូលដ្ឋានផលិតកម្ម។ មានការបង្ហាញឲ្យដឹងថា និន្នាការ "ប្រទេសថៃបូកមួយ" និងការពង្រីកតំបន់ឆ្លងកាត់ព្រំដែនបន្ថែមទៀតមិនអាចទៅរួចឡើយដោយសារកង្វះកម្លាំងពលកម្មធ្ងន់ធ្ងរនៅក្នុងតំបន់ព្រំដែន។ ជាងនេះទៅទៀត ក្រុមហ៊ុនអាជីវកម្មក៏អះអាងផងដែរថា កម្រិតវប្បធម៌មូលដ្ឋាន និងការបណ្តុះបណ្តាលវិជ្ជាជីវៈមិនគ្រប់គ្រាន់នាំឲ្យមានកង្វះខាតបុគ្គលិកជំនាញ ដែលបណ្តាលឲ្យមានការកែលម្អតិចតួចទៅលើគុណភាព និងការជំរុញផលិតភាពនៅមានកម្រិតនៅក្នុងអនុតំបន់។ បញ្ហាប្រឈមទាំងនេះត្រូវបានមើលឃើញថាជា បញ្ហាប្រឈមចម្បងចំពោះការអភិវឌ្ឍឧស្សាហកម្មសម្រាប់ការអភិវឌ្ឍរយៈពេលមធ្យម និងរយៈពេលវែងនៅក្នុងអនុតំបន់។

ដូចដែលបានលើកឡើងនៅក្នុងផែនការ AEC លំហូរដោយសេរីនូវបុគ្គលិកជំនាញមានសារសំខាន់ចំពោះការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវធនធានពលកម្មជំនាញនៅក្នុងអនុតំបន់ទន្លេមេគង្គ។ ចំពោះពលកម្មគ្មានជំនាញ ខណៈដែលលំហូរដោយភាពបត់បែន និង

ដោយគ្មានឧបសគ្គនូវកម្លាំងពលកម្មនៅក្នុងតំបន់អាចទាក់ទាញក្រុមហ៊ុនផ្សេងៗ អ្វីដែលជាកង្វល់គឺថា គម្លាតប្រាក់ឈ្នួលដោយសារកម្រិតខុសគ្នានៃការអភិវឌ្ឍឧស្សាហកម្មជាតិនៅក្នុងអនុតំបន់អាចបណ្តាលឲ្យមានចំណាកស្រុកកម្លាំងពលកម្មធ្ងន់ធ្ងរ។ កត្តានេះអាចនាំមកនូវការប្តូរទីតាំងដោយជៀសមិនផុតនូវរោងចក្រឧស្សាហកម្មនៅក្នុងតំបន់។

**3. រចនាសម្ព័ន្ធឧស្សាហកម្មទូទាំងតំបន់ទន្លេមេគង្គនាពេលអនាគត**

○ ប្រទេសថៃដែលជាប្រទេសមានសេដ្ឋកិច្ចនាំមុខគេនៅក្នុងអនុតំបន់ទន្លេមេគង្គគួរដឹកនាំនៅក្នុងការធ្វើឧស្សាហាភាវូបនីយកម្ម និងលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាទៅកាន់បណ្តាប្រទេសទន្លេមេគង្គផ្សេងទៀត។ តាមរយៈការប្រើប្រាស់បណ្តុំយានយន្ត និងអេឡិចត្រូនិកដែលមានស្រាប់ និងការទាញយកប្រយោជន៍ពីឋានៈរបស់ខ្លួនជាអ្នកវិនិយោគឈានមុខដែលមានបណ្តុំមូលធនធំបំផុត ប្រទសថៃអាចជំរុញឧស្សាហកម្ម និងបច្ចេកវិទ្យាក្នុងស្រុក ស្របពេលពង្រីកសង្វាក់ផ្គត់ផ្គង់របស់ខ្លួនទៅកាន់អនុតំបន់ទាំងមូល។ ឧទាហរណ៍ ក្រៅពីដំណើរការដំឡើងចុងក្រោយ និងផលិតគ្រឿងបន្លាស់ ដំណើរការគុណតម្លៃថៃកាន់តែខ្ពស់ និងមូលដ្ឋាន R&D អាចធ្វើការអភិវឌ្ឍនៅក្នុងប្រទេសថៃ (ឧទាហរណ៍ ការអភិវឌ្ឍ និងភ្ជាប់កម្មវិធីផ្នែកទន់ ECU នៅក្នុងឧស្សាហកម្មយានយន្ត ការផលិតគ្រឿងបន្លាស់ទូទៅ និងការខាត់ដោយសារធាតុគីមីពិសេសនៅក្នុងឧស្សាហកម្មអេឡិចត្រូនិក)។

○ ទោះបីជាប្រទេសវៀតណាមគឺជាប្រទេសមានប្រាក់ចំណូលមធ្យម មូលដ្ឋានរឹងមាំនៃការគាំទ្រវិស័យឧស្សាហកម្មមិនទាន់មានការរីកចម្រើននៅក្នុងប្រទេសនៅឡើយទេ ប៉ុន្តែប្រទេសវៀតណាមគួរប្រើប្រាស់សក្តានុពលរបស់ខ្លួនជាប្រទេសដែលមានចំនួនប្រជាជនច្រើនបំផុតនៅក្នុងអនុតំបន់ដែលមានឆ្នេរសមុទ្រវែងអន្លាយ និងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែសមុទ្រទឹកជ្រៅ

ដែលផ្តល់នូវមធ្យោបាយល្អបំផុតសម្រាប់ការដឹកជញ្ជូនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និង សហភាពអឺរ៉ុប និងតំបន់ដែលមានភូមិសាស្ត្រនៅជិតភាគខាងត្បូងនៃប្រទេសចិនដែលជាបណ្តុំអេឡិចត្រូនិកធំបំផុត។ គោលនយោបាយឧស្សាហកម្មស៊ីសង្វាក់គ្នាដែលមានចាប់ពីការជំរុញតម្រូវការ ការអភិវឌ្ឍធនធានមនុស្ស សេរីភាវូបនីយកម្មពាណិជ្ជកម្ម និង គោលនយោបាយ ជំរុញការវិនិយោគអាចជួយសម្រួលដល់ការវិនិយោគផ្ទាល់ពីបរទេសពីប្រទេសជប៉ុន ប្រទេសចិន និងប្រទេសកូរ៉េចូលក្នុងវិស័យនានា ដូចជាវិស័យយានយន្ត និងអេឡិចត្រូនិកជាដើម។ ប្រទេសវៀតណាមបានចាប់ផ្តើមទាក់ទាញ FDI ពីប្រទេសជប៉ុន និងប្រទេសចិននៅក្នុង ដំណើរការដើមខ្សែដូចជា រវៃអំបោះ ឬដំណើរការច្បាស់លាស់នៅក្នុងការផលិត។ ប្រទេស វៀតណាមអាចជំរុញឧស្សាហកម្មដើមខ្សែតាមរយៈការអនុវត្តគោលនយោបាយដោយប្រើប្រាស់កិច្ចខិតខំប្រឹងប្រែង EPA ឈានមុខដូចជា TPP, RCEP និងជាមួយសហភាពអឺរ៉ុប។

○ ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងប្រទេសមីយ៉ាន់ម៉ាកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៃឧស្សាហាភាវូនីយកម្ម ហើយដូច្នេះចំណុចជាអាទិភាពគឺត្រូវជំរុញវិស័យឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្ម និងធនធានធម្មជាតិដែលមានចំនួនច្រើនលើសលប់ ដូចជាកសិកម្ម និងនេសាទ កែច្នៃចំណីអាហារ និងទេសចរណ៍។ នៅក្នុងរយៈពេលខ្លី អាទិភាពមួយទៀតគឺការចូលរួមនៅក្នុងបណ្តាញផលិតកម្មសកលដោយអញ្ជើញប្លុកផលិតកម្មពីបណ្តាប្រទេសផ្សេងៗទៀត រួមទាំងដំណើរការប្រពលវប្បកម្មពលកម្ម និង កាត់បន្ថយចំណាយបណ្តាញសេវា។ កត្តានេះអាចលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់ក្រុមហ៊ុនក្នុងស្រុក និងពង្រឹងកម្រិតកម្លាំងពលកម្មដោយប្រើប្រាស់បច្ចេកវិទ្យាហួរហៀរពី

បណ្ដាញផលិតកម្មសកល។

ទោះបីជាយ៉ាងណា ទីតាំងដំណើរការប្រពលវប្បកម្មពលកម្មអាចផ្លាស់ប្ដូរបាន។ ដូច្នេះ នៅក្នុងដំណើរការរយៈពេលវែង ការអភិវឌ្ឍឧស្សាហកម្មដែលបំពេញឲ្យតំបន់/ប្រទេសជិតខាង និងដែលប្រើប្រាស់ចំណុចខ្លាំងមានស្រាប់របស់ប្រទេសគឺជាចំណុចសំខាន់។

ឧទាហរណ៍ ជាមួយនឹងសមត្ថភាព CMT មានស្រាប់ ប្រទេសកម្ពុជា និងមីយ៉ាន់ម៉ាអាចទាក់ទាញដំណើរការគុណតម្លៃបន្ថែមកាន់តែខ្ពស់ ដូចជាវវៃអំបោះ និងតម្បាញ ឬការរៀបចំផែនការផលិតផល។ ជាងនេះទៅទៀត ដើម្បីកំណើនរយៈពេលវែងនៅក្នុងឧស្សាហកម្មគុណតម្លៃបន្ថែមខ្ពស់ និងមធ្យមការអភិវឌ្ឍសេវាភ័ស្ដុភាជាស្នូលនៃឧស្សាហកម្មទាំងអស់រួមទាំង ឧស្សាហកម្មការដឹកជញ្ជូនដែលរួមបញ្ចូលការវេចខ្ចប់ និងត្រួតពិនិត្យ ការពង្រីកសេវាថែទាំ និងការផលិតគ្រឿងបង្គុំ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគឺមានសារសំខាន់។

ដោយមានធនធានទឹកច្រើនលើសលុប ដីមានជីជាតិ និងថ្លៃពលកម្មទាប សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវអាចមានគុណសម្បត្តិប្រកួតប្រជែងនៅក្នុងការបង្កើតឧស្សាហកម្មគ្រឿងយន្តច្បាស់លាស់ (ឧទាហរណ៍ ដំណើរការខាត់លែន) ឧស្សាហកម្មកែច្នៃរ៉ែ ឧស្សាហកម្មកែច្នៃ កសិផល ឧស្សាហកម្មគ្រឿងអគ្គិសនី និងបង្គុំអេឡិចត្រូនិក។ ធនធានធម្មជាតិច្រើនលើសលប់មិនត្រឹមតែផ្ដល់សក្ដានុពលដល់ការនាំចេញវត្ថុធាតុដើមប៉ុណ្ណោះទេ ប៉ុន្ដែថែមទាំងផ្ដល់ ឱកាសក្នុងការអភិវឌ្ឍឧស្សាហកម្មដោយកែច្នៃធនធាននៅក្នុងតំបន់ និងផលិតនូវតម្លៃបន្ថែមផងដែរ។

ជាងនេះទៅទៀត ប្រសិទ្ធភាពកាន់តែខ្ពស់នៅក្នុងការផលិត និងបញ្ជូនអគ្គិសនីអាចផ្តល់ថាមពលដល់វិស័យកម្មន្តសាលនៅក្នុងអនុតំបន់ទន្លេមេគង្គ។

○ រួមជាមួយនឹងឧស្សាហាភាវូនីយកម្មខាងលើ និងការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្ម គេអាចព្យាករណ៍បានថា បញ្ហាប្រឈមនឹងកើតចេញពីគម្លាតអភិវឌ្ឍរវាងតំបន់ទីក្រុង និងតំបន់ជនបទ ដូចជាការថយចុះចំនួនប្រជាជនជនបទ និងគម្លាតប្រាក់ចំណូលកាន់តែធំឡើង។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ជាការសំខាន់គឺត្រូវកំណត់វិស័យកសិកម្ម និងឧស្សាហកម្មចំណីអាហារ និងឧស្សាហកម្មចម្បងៗនៃតំបន់ជនបទជាវិស័យយុទ្ធសាស្ត្រដែលបង្កើតសង្វាក់គុណតម្លៃចំណីអាហារ និងលើកកម្ពស់ការអភិវឌ្ឍវិស័យទាំងនោះឲ្យទៅជាវិស័យគុណតម្លៃបន្ថែមខ្ពស់ជាងមុន។ ការពិចារណាលើកំណើនតម្រូវការចំណីអាហារនៅក្នុងតំបន់អាស៊ីខាងកើត ព្រមទាំងគុណសម្បត្តិធម្មជាតិ និងប្រជាសាស្ត្រនៃអនុតំបន់ទន្លេមេគង្គ ការលើកទឹកចិត្តការធ្វើកសិកម្ម និងការកែច្នៃបន្លែ/ផ្លែឈើសំខាន់មួយចំនួនជាឧស្សាហកម្មនាំចេញជាយុទ្ធសាស្ត្រដោយយកចិត្តទុកដាក់ខ្ពស់ចំពោះសុវត្ថិភាពចំណីអាហារអាចមានសក្តានុពលល្អ។ ការអភិវឌ្ឍវិស័យវិស័យឧស្សាហកម្ម និងការកែច្នៃចំណីអាហារនឹងលើកកម្ពស់ដល់វិស័យកម្មន្តសាល (ការផលិតគ្រឿងចក្រកសិកម្ម និងគ្រឿងម៉ាស៊ីនកែច្នៃចំណីអាហារ) និងវិស័យសេវាពាក់ព័ន្ធផ្សេងៗ (សេវាដឹកជញ្ជូនខ្សែសង្វាក់នៃការរក្សាសីតុណ្ហភាពត្រជាក់ ហាងលក់រាយចំណីអាហារ និងសេវាចំណីអាហារ) នៃសង្វាក់គុណតម្លៃពាក់ព័ន្ធ។ ជាងនេះទៅទៀត ការធ្វើសមាហរណកម្មវិស័យឧស្សាហកម្ម និងវិស័យពាក់ព័ន្ធនឹងចំណីអាហារនឹងជួយឲ្យវិស័យកសិកម្មក្លាយជាវិស័យមួយដែលហៅថា "វិស័យទីប្រាំមួយ (លាយគ្នារវាងវិស័យទីមួយ វិស័យទីពីរ និងវិស័យទីបី) និងបន្ថែមតម្លៃដល់វិស័យឧស្សាហកសិកម្ម។

កត្តានេះអាចនាំទៅរកការបង្កើតសង្វាក់គុណតម្លៃចំណីអាហារនៅក្នុងអនុតំបន់ទន្លេមេគង្គ និងការចូលរួមនៅក្នុងសង្វាក់គុណតម្លៃចំណីអាហារសកល។

ឧទាហរណ៍ ការធ្វើម៉ាស៊ីនភាវូបនីយកម្មនៃវិស័យឧស្សាហកម្មនៅក្នុងអនុតំបន់ទន្លេមេគង្គនឹងលើកទឹកចិត្តដល់ការកំណត់យកទីតាំងកម្មន្តសាលម៉ាស៊ីន បំពេញចន្លោះខ្វះខាតនៃពលកម្មកសិកម្មដោយលើកកម្ពស់ផលិតភាព និងគាំទ្រដល់ការផ្ទេរពលកម្មពីឧស្សាហកម្មទីមួយទៅឧស្សាហកម្មទីពីរ និងទីបី។ ជាងនេះទៅទៀត ការអភិវឌ្ឍឧស្សាហកម្មសេវាដឹកជញ្ជូនដែលផ្តល់ភ័ស្តុភារសង្វាក់រក្សាសីតុណ្ហភាពត្រជាក់នឹងជួយលើកកម្ពស់ដល់សមត្ថភាពប្រកួតប្រជែងនៃការនាំចេញផលិតផលកសិកម្ម ព្រមទាំងជំរុញដល់ប្រព័ន្ធចែកចាយបែបប្រពៃណីនៃផលិតផលកសិកម្ម។ ជាងនេះទៅទៀត កសិករ និងឧស្សាហកម្មខ្នាតតូច និងមធ្យមអាចទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចផ្សេងៗទៀត ដូចជាប្រាក់ចំណូលកើនឡើងសម្រាប់កសិករ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ តាមរយៈការមានសមត្ថភាពចូលទៅកាន់ទីផ្សារដោយផ្ទាល់ ដោយសារការសម្រេចបាននូវ "ឧស្សាហកម្មទីប្រាំមួយ"។

○ តាមរយៈការសម្រេចបាននូវរចនាសម្ព័ន្ធឧស្សាហកម្មប្រសើរបំផុតនៅទូទាំងតំបន់ទន្លេមេគង្គ <u>ចក្ខុវិស័យដែលប្រទេសជប៉ុន និងបណ្តាប្រទេសទន្លេមេគង្គមានរួមគ្នាគឺសង្គមមួយដែលពលរដ្ឋគ្រប់រូបនៅក្នុងអនុតំបន់ទន្លេមេគង្គអាចរស់នៅ "ដោយភាពថ្កុំថ្កើង" ដែលវប្បធម៌ ប្រពៃណីនៃប្រទេសនីមួយៗ និងបរិស្ថានធម្មជាតិនៅតែមានភាពគង់វង្ស ហើយការធ្វើឧស្សាហាភាវូបនីយកម្មនាំមកនូវគុណភាពជីវិតកាន់តែប្រសើរ និងលើកស្ទួយដល់ការប្រើប្រាស់ផងដែរ។</u>

○ រដ្ឋាភិបាល និងក្រុមហ៊ុនជប៉ុននឹងបន្តសហការជាមួយបណ្តាប្រទេស និងក្រុមហ៊ុននៅក្នុងតំបន់ទន្លេមេគង្គក្នុងកាត់បន្ថយគម្លាតក្នុងចំណោមប្រទេស និងទីក្រុង <u>ដោយផ្អែកលើជំនឿថា</u>

កំណើនដោយសមធម៌ និងមានតុល្យភាពនឹងចូលរួមចំណែកដល់ការអភិវឌ្ឍ និងភាពថ្កុំថ្កើង ទាំងសម្រាប់ប្រទេសជប៉ុន និងបណ្តាប្រទេសទន្លេមេគង្គ។

**4.ទិសដៅគោលនយោបាយ**

- ឆ្ពោះទៅការពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក និងការពង្រីកសង្វាក់ផ្គត់ផ្គង់នៅក្នុងអនុតំបន់ទន្លេមេគង្គ 1) ការចាប់ដៃគូជាមួយបណ្តាប្រទេសជិតខាង 2) ការកសាងមូលដ្ឋានសម្រាប់រចនាសម្ព័ន្ធឧស្សាហកម្មកាន់តែទំនើប និង 3) ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងធនធានដែលគាំទ្រដល់សង្វាក់គុណតម្លៃក្នុងតំបន់ គឺមានភាពចាំបាច់។ កិច្ចខិតខំប្រឹងប្រែងទូទាំងតំបន់ទាំងនេះនឹងត្រូវអនុវត្តនៅត្រឹមឆ្នាំ2020 ហើយផលិតផលក្នុងស្រុកសរុបរំពឹងថានឹងកើនឡើងចំនួន20ពាន់លានដុល្លារនៅក្នុងប្រទេសតំបន់ទន្លេមេគង្គដែលកើតចេញពីចក្ខុវិស័យនេះ (ដូចជាចំនួន2.0%នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសតំបន់ទន្លេមេគង្គ)។ បន្ទាប់មកទៀត អនុតំបន់ដើរតួនាទីសំខាន់ជាស្នូលនៃបណ្តាញសង្វាក់គុណតម្លៃអាស៊ី និងបង្កើតមូលដ្ឋានសម្រាប់កំណើនសេដ្ឋកិច្ចបន្ថែមទៀតដែលមានផលប្រយោជន៍សេដ្ឋកិច្ចនៃសេដ្ឋកិច្ចធំដែលមានកំណើនឆាប់រហ័សនៅប្រទេសជិតខាងចំនួនពីរគឺប្រទេសចិន និងប្រទេសឥណ្ឌា។
- រដ្ឋាភិបាលជប៉ុនបន្តផ្តល់កិច្ចគាំទ្រ និងលើកកម្ពស់កិច្ចសហការជាមួយរដ្ឋាភិបាលនៅក្នុងបណ្តាប្រទេសទន្លេមេគង្គនៅក្នុងការបង្កើតគោលនយោបាយឧស្សាហកម្ម ដើម្បីសម្រេចនូវចក្ខុវិស័យ និងដោះស្រាយបញ្ហានីមួយៗដែលប្រទេសនីមួយៗកំពុងជួបប្រទះ (ឧទាហរណ៍

យុទ្ធសាស្ត្រឧស្សាហាភាវូបនីយកម្មរបស់ប្រទេសវៀតណាម)។

(1) **ការចាប់ដៃគូជាមួយប្រទេសជិតខាង**

<ការកែលម្អរចនាសម្ព័ន្ធពាណិជ្ជកម្ម>

សមត្ថភាពប្រកួតប្រជែងវិស័យឧស្សាហកម្មរបស់អនុតំបន់ទន្លេមេគង្គគួរធ្វើការលើកកម្ពស់បន្ថែមទៀតបើប្រៀបធៀបជាមួយតំបន់ផ្សេងៗទៀតដើម្បីក្លាយជាទីតាំងផលិតកម្ម និងមូលដ្ឋាននាំចេញនៃតំបន់អាស៊ីទាំងមូល ដែលផ្តល់ថាមពលដោយ AEC និង RCEP។

គោលនយោបាយថ្នាក់តំបន់ពាក់ព័ន្ធនឹងពាណិជ្ជកម្មឆ្លងកាត់ព្រំដែនគួរធ្វើការបង្រួបបង្រួមនៅក្នុងតំបន់ទន្លេមេគង្គទាំងមូលដើម្បីបង្កើតសង្វាក់គុណតម្លៃតំបន់ឆ្ពោះទៅសង្វាក់គុណតម្លៃសកលដែលគាំទ្រដល់លំហូរទំនិញដោយរលូនរវាងបណ្តាប្រទេសនៅក្នុងអនុតំបន់។ ការពង្រឹងគោលនយោបាយដែលទាក់ទាញឧស្សាហកម្មដែលប្រើប្រាស់ចំណុចខ្លាំងមានស្រាប់របស់ប្រទេសនីមួយៗគួរកំណត់ជាអាទិភាពដើម្បីជំរុញជាលក្ខណៈយុទ្ធសាស្ត្រនូវឧស្សាហកម្មនាំចេញ ការធ្វើសមាហរណកម្មទូទាំងតំបន់នូវសង្វាក់គុណតម្លៃ និងការកសាងភាពជាដៃគូបំពេញបន្ថែមរវាងប្រទេសនីមួយៗ (ឧទាហរណ៍ ការបង្កើត និងការបញ្ជាក់ស្តង់ដារ ការកសាងសង្វាក់រក្សាសីតុណ្ហភាពត្រជាក់កម្រិតស្តង់ដារសកល និងការកសាងសមត្ថភាព)

ក្រៅពីនេះ គួរអនុវត្តកិច្ចខិតខំប្រឹងប្រែងគ្រប់ជ្រុងជ្រោយដើម្បីជំរុញ "ឧស្សាហកម្មថ្មី" (ឧទាហរណ៍ ការថែទាំសុខភាព ឧស្សាហកម្មផ្សព្វផ្សាយ បៃតង និងថាមពល និងការដើបឡើងវិញ) ដែលជួយដោះស្រាយបញ្ហាប្រឈមសង្គមដែលបណ្តាប្រទេសទន្លេមេគង្គកំពុងជួបប្រទះ។

<ជំរុញការវិនិយោគផ្ទាល់ពីបរទេស (FDI) តាមរយៈតំបន់សេដ្ឋកិច្ចពិសេស (SEZ)>

ដើម្បីលើកកម្ពស់ភាពទាក់ទាញ SEZ ទីក្រុង និងតាមព្រំដែនចំពោះអ្នកវិនិយោគជប៉ុន ព័ត៌មានលម្អិតនឹងត្រូវផ្តល់ជូន រួមជាមួយការិយាល័យគាំទ្រ ដោយចាប់ដៃគូជាមួយភាគីពាក់ព័ន្ធផ្សេងៗដូចជា JETRO មជ្ឈមណ្ឌលអាស៊ានជប៉ុន។

ពាក់ព័ន្ធនឹងការបង្កើត SEZ តាមតំបន់ព្រំដែន ការធ្វើឯកទេសកម្ម និងកិច្ចសហការរវាង SEZ ប្រទេសថៃ និង SEZ ក្នុងប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងប្រទេសមីយ៉ាន់ម៉ាគួរធ្វើការពិចារណាឲ្យបានម៉ត់ចត់ និងពិភាក្សាគ្នាឲ្យបានល្អិតល្អន់រវាងបណ្តាប្រទេសទាំងនោះដើម្បីសម្រេចឲ្យបានយុទ្ធសាស្ត្រ "ឈ្នះៗ" សម្រាប់ភាគីពាក់ព័ន្ធទាំងអស់។ ឧទាហរណ៍ នៅក្នុងវេទិកាពិភាក្សារវាងរដ្ឋាភិបាល-វិស័យឯកជនក្នុងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ រដ្ឋាភិបាលថៃត្រូវបានស្នើឲ្យជួយសម្រាលភាពរាំងស្ទះនៅតាមព្រំដែនតាមរយៈការកែលម្អមជ្ឈមណ្ឌលភស្តុភា ឬកែលម្អគុណភាពជីវិតនៅតាមតំបន់ព្រំដែនតាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម និងលំនៅដ្ឋាន។

<កិច្ចសហការអាជីវកម្មក្នុងស្រុក>

កិច្ចសហការអាជីវកម្មគួរធ្វើការកែលម្អតាមរយៈការបង្កើត និងពង្រឹងវិធាន M&A និងគោលការណ៍គណនេយ្យដែលប្រកបដោយតម្លាភាព ជំរុញកិច្ចសហការដើម្បីជំរុញទាំងទីផ្សារ ឥណទាន និងមូលបត្រ និងតាមរយៈការកសាងប្រព័ន្ធស្តង់ដារផ្សេងៗទៀតរវាងអនុតំបន់ និងប្រទេសជប៉ុនស្របទៅតាមច្បាប់ និងវិធានរបស់ប្រទេសនីមួយៗ។ ការកសាងសមត្ថភាព និងផ្ទេរព័ត៌មានគួរទទួលបានការលើកទឹកចិត្តដើម្បីឆ្ពោះទៅសម្រេចគោលដៅនេះ។ ពិព័រណ៍ពាណិជ្ជកម្ម បេសកកម្មពាណិជ្ជកម្ម និងសិក្ខាសាលាវិនិយោគទៅវិញទៅមកគួរទទួលបានការជំរុញទឹកចិត្តដើម្បីផ្តល់នូវឱកាសត្រូវគ្នាផ្នែកអាជីវកម្មសម្រាប់អ្នកវិនិយោគបរទេស រួមទាំងសហគ្រាសខ្នាតតូច និង

មធ្យម និងសហគ្រាសក្នុងស្រុកនៅក្នុងអនុតំបន់។

**(2) ការកសាងមូលដ្ឋានសម្រាប់រចនាសម្ព័ន្ធឧស្សាហកម្មឲ្យកាន់តែមានលក្ខណៈទំនើប**

<ការជំរុញ R&D>

កិច្ចខិតខំប្រឹងប្រែង R&D ទូលំទូលាយគួរផ្តោតទៅលើការអភិវឌ្ឍផលិតផលដែលបណ្តាប្រទេសទន្លេមេគង្គប្រើប្រាស់អត្ថប្រយោជន៍ប្រៀបធៀបរបស់ខ្លួន "នៅជិតមូលដ្ឋានផលិតកម្ម" បាតុកម្មដែលជាបញ្ហាប្រឈមនៃការសម្រេចបាននូវសង្គមមានចីរភាព និងការជំរុញវិស័យឧស្សាហកម្មដោយប្រើប្រាស់លលក្ខណៈនៅក្នុងតំបន់ទន្លេមេគង្គ ឬបញ្ហាដែលបណ្តាប្រទេសទន្លេមេគង្គកំពុងជួបប្រទះក្នុងពេលបច្ចុប្បន្ន ដែលមានដូចជា គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ថាមពល/ទឹកដែលគ្មានប្រសិទ្ធភាព និងការពឹងផ្អែកទៅលើឥន្ធនៈផូស៊ីល។

វគ្គសិក្សា និងកម្មវិធីហាត់ការគួរបង្កើតឡើងដោយសហការជាមួយសាកលវិទ្យាល័យ និងឧស្សាហកម្មជប៉ុនដើម្បីជំរុញឲ្យមានក្រុមការងារ និងអ្នកគ្រប់គ្រងដែលមានជំនាញខ្ពស់ផ្នែកវិទ្យាសាស្ត្រ និងវិស្វកម្ម។ ការវិនិយោគអភិវឌ្ឍន៍ផលិតផលគួរធ្វើពង្រឹងដើម្បីឲ្យការអភិវឌ្ឍផលិតផលស្របទៅនឹងតម្រូវការទីផ្សារទំនើប និងទូលំទូលាយ និងស្របតាមឧស្សាហកម្មកម្មន្តសាល។

< សមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសខ្នាតតូច និងមធ្យម>

តាមរយៈការប្រកាន់ខ្ជាប់នូវការអនុវត្ត "ផែនការសកម្មភាពយុទ្ធសាស្ត្រអាស៊ានសម្រាប់អភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម (2016–2025)" ការលើកកម្ពស់សមត្ថភាពរបស់ SME សម្រាប់ការច្នៃប្រឌិត និងអន្តរភាវូនីយកម្មគួរត្រូវបានជំរុញ។

### (3) ការពង្រឹងហេដ្ឋរចនាសម្ព័ន្ធ និងធនធានដែលគាំទ្រដល់សង្វាក់គុណតម្លៃក្នុងតំបន់

<បណ្តាញតភ្ជាប់ក្នុងតំបន់>

បណ្តាញតភ្ជាប់គួរធ្វើការកែលម្អ ជាពិសេសតាមរយៈការបង្កើតច្រកសេដ្ឋកិច្ចខាងលិច-កើត ច្រកសេដ្ឋកិច្ចខាងត្បូង និងបណ្តាញតភ្ជាប់ភាគខាងជើង និងខាងត្បូងប្រទេសវៀតណាមនៅក្នុងអនុតំបន់ទន្លេមេគង្គ។ ជាពិសេសត្រូវកំណត់អាទិភាពខ្ពស់លើការកែលម្អបណ្តាញតភ្ជាប់ច្រើនសេដ្ឋកិច្ចភាគខាងលិច-កើត និងច្រកសេដ្ឋកិច្ចភាគខាងត្បូងប្រទេសមីយ៉ាន់ម៉ាដែលមានបញ្ហា ប្រឈមត្រូវការកំពង់ផែសមុទ្រទឹកជ្រៅដែលនឹងជួយប្រទេសឥណ្ឌា និងមជ្ឈិមបូព៌ាឲ្យកាន់តែងាយស្រួលចូលដល់។

ការបង្កើតសង្វាក់ផ្គត់ផ្គង់ឆ្លងកាត់ព្រំដែននឹងតម្រូវឲ្យមានការកាត់បន្ថយថ្លៃចំណាយពាណិជ្ជកម្មមិនត្រឹមតែពាក់ព័ន្ធនឹងប្រាក់ទេ ប៉ុន្តែថែមទាំងពេលវេលា និងភាពអាចជឿជាក់បាននៃវិស័យដឹកជញ្ជូនផងដែរ។ ដោយផ្អែកលើការទទួលស្គាល់ដែលបានរៀបរាប់ខាងលើ កិច្ចខិតខំប្រឹងប្រែងគ្រប់ជ្រុងជ្រោយគួរផ្តោតទៅលើកិច្ចការខាងក្រោមដែលមានដូចជា៖

- បំពេញតម្រូវការនូវការអភិវឌ្ឍរចនាសម្ព័ន្ធដ៏ច្រើននៅក្នុងបណ្តាប្រទេសទន្លេមេគង្គ ប្រទេសជប៉ុនលើកកម្ពស់ "ការវិនិយោគរចនាសម្ព័ន្ធប្រកបដោយគុណភាព" ដោយសហការជាមួយបណ្តាប្រទេសផ្សេងៗទៀត អង្គការអន្តរជាតិរួមទាំងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត មិនត្រឹមតែតាមហិរញ្ញវត្ថុសាធារណៈទេ ប៉ុន្តែតាមរយៈការអភិវឌ្ឍ និងលើកកម្ពស់យន្តការដែលទាក់ទាញមូលនិធិឯកជនឆ្ពោះទៅការវិនិយោគលើហេដ្ឋរចនាសម្ព័ន្ធនៅក្រោម "ភាពជាដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព៖

ការវិនិយោគសម្រាប់អនាគតតំបន់អាស៊ី" ដែលនាយករដ្ឋមន្ត្រី Abe បានប្រកាសកាលពីខែឧសភា ឆ្នាំ2015។

- រួមគ្នារៀបចំសិក្ខាសាលាជាមួយមន្ត្រីរបស់ភាគីពាក់ព័ន្ធដើម្បីបានស្តាប់អំពីទស្សនៈរបស់អ្នកវិនិយោគអំពីបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការដឹកជញ្ជូនទូទាំងតំបន់ទន្លេមេគង្គ និងពិភាក្សាអំពីវិធីដោះស្រាយបញ្ហាទាំងនេះ រួមទាំងបញ្ហាប្រឈមជាក់ស្តែងរបស់ CBTA ផងដែរ
- ជំរុញការសម្របសម្រួលពាណិជ្ជកម្មតាមរយៈការធ្វើទំនើបកម្មគយ
- ស្រាវជ្រាវដើម្បីកំណត់កាប្រើប្រាស់ប្រសើរបំផុតនៃជម្រើសដឹកជញ្ជូនគំរូចម្រុះ (ដូចជា ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស) ដោយចេញពីទស្សនវិស័យប្រសិទ្ធភាពថ្លៃចំណាយ/ថាមពល។

<ការផ្គត់ផ្គង់ថាមពល និងបរិស្ថាន>

- ផែនការថាមពល និងអគ្គិសនីសមស្របដោយគិតគូរអំពីភាពចម្រុះនៃរបាយថាមពល និងទទួលបានប្រសិទ្ធផលខ្ពស់ និងការពិភាក្សាអំពីបរិស្ថានគួរត្រូវបានបង្កើតឡើងដើម្បីសម្រេចបានសមតាប្រកបដោយស្ថិរភាពរវាងការផ្គត់ផ្គង់ និងតម្រូវការថាមពលនៅកម្រិតថ្នាក់ជាតិនីមួយៗ។ ការផ្គត់ផ្គង់អគ្គិសនីឆ្លងកាត់ព្រំដែនដោយផ្អែកលើក្រឡាចក្រត្រង្គថាមពលអាស៊ានអាចជាចម្រើសមួយ។ ការសម្រេចបាននូវផែនការតភ្ជាប់ទៅវិញទៅមកនូវក្រឡាចក្រត្រង្គថាមពលដូចដែលបានជំរុញដោយ HAPUA (ប្រធានសេវា/អាជ្ញាធរថាមពលអាស៊ាន) គួរកំណត់យកជាជម្រើសមួយ។

ពាក់ព័ន្ធនឹងការផ្គត់ផ្គង់ថាមពលក្នុងតំបន់ រោងចក្រផលិតថាមពលគួរត្រូវបានបង្កើតឡើងដើម្បីសម្រេចភាពចម្រុះដែលអាចមានប្រសើរបំផុតនៃរបាយថាមពលក្នុងតំបន់។ ការអនុវត្តផលិតផលថាមពលដូចដែលបានកំណត់នៅក្នុងក្របខណ្ឌវិនិយោគតំបន់ GMS (RIF) និងការបង្កើតមជ្ឈមណ្ឌលសម្របសម្រួលថាមពលតំបន់ (RPCC) គឺជាធាតុគន្លឹះដើម្បីធានា

សន្តិសុខថាមពលសម្រាប់តំបន់។ ពាក់ព័ន្ធនឹងរោងចក្រថាមពលនីមួយៗ ជាប្រការសំខាន់គឺត្រូវលើកកម្ពស់វិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធគុណភាពខ្ពស់ និងមានសមត្ថភាពខ្ពស់ជាងមុន ដូចជារោងចក្រថាមពលដុតធ្យូងដែលមានប្រសិទ្ធផលខ្ពស់ ដើម្បីលើកកម្ពស់សន្តិសុខថាមពល រួមចំណែកក្នុងការកាត់បន្ថយចំណាយលើឥន្ធនៈ និងជួយសម្រាលបញ្ហាការប្រែប្រួលអាកាសធាតុ។

- បរិយាកាសវិនិយោគគួរលើកកម្ពស់ដើម្បីរក្សាស្ថិរភាពនៃការអភិវឌ្ឍប្រេង និងឧស្ម័នតាមរយៈនីតិវិធីរហ័ស និងការគ្រប់គ្រងស្ថាប័នក្នុងស្រុកប្រកបដោយស្ថិរភាព។
- វិធានការគោលនយោបាយរឹងមាំដែលជំរុញ EE&C ថាមពលកកើតឡើងវិញ និងសហគមន៍/ក្រឡាចក្រត្រង្គវៃឆ្លាតគួរធ្វើការលើកកម្ពស់បន្ថែមទៀត។
- ស្របពេលជាមួយគ្នានេះដែរ ការជំរុញសរសៃឈាមឧស្សាហកម្មគួរគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្មប្រកបដោយចីរភាព និងអនុគ្រោះដល់ប្រព័ន្ធអេកូឡូស៊ី។
- គួរពិចារណាអំពីកិច្ចខិតខំប្រឹងប្រែងនៅក្នុងការទប់ស្កាត់គ្រោះមហន្តរាយដើម្បីបង្កើតសង្វាក់ផ្គត់ផ្គង់ដែលងាយស្តារឡើងវិញ។

< ការអភិវឌ្ឍធនធានមនុស្ស>

ប្រទេសថៃមានបណ្តុំឧស្សាហកម្មធំជាងគេនៅក្នុងអនុតំបន់ទន្លេមេគង្គ និងអាចក្លាយជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សដ៏មានសក្តានុពល និងចូលរួមចំណែកនៅក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងតំបន់ដោយផ្តល់នូវការអនុវត្តប្រសើរបំផុត។ ដើម្បីផ្តល់នូវធនធានមនុស្សចាំបាច់ជាប្រចាំសម្រាប់ការធ្វើឧស្សាហាភាវូបនីយកម្មរបស់ប្រទេសនីមួយៗ គួរអនុវត្តនូវកិច្ចខិតខំប្រឹងប្រែងដូចខាងក្រោម៖

- ដើម្បីអភិវឌ្ឍគោលនយោបាយ HRD ឲ្យមានប្រសិទ្ធភាព ដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍធនធានមនុស្សរបស់ប្រទេសនីមួយៗគួរធ្វើការវាយតម្លៃឲ្យបានសមស្រប ដែលផ្អែកទៅលើការវាយតម្លៃនេះគោលនយោបាយ HRD ល្អិតល្អន់ដើម្បីដោះស្រាយបញ្ហានៅក្នុងប្រទេសនីមួយៗគួរត្រូវបានបង្កើតឡើង។
- កិច្ចខិតខំប្រឹងប្រែងគួរផ្តោតទៅលើផ្នែករដ្ឋាភិបាលដើម្បីកែលម្អការអប់រំកម្រិតមូលដ្ឋាន និងការអប់រំកម្រិតខ្ពស់ រួមទាំងការគាំទ្រដល់សាកលវិទ្យាល័យឈានមុខ (ជាពិសេសលើជំនាញវិស្វកម្ម) និង AUN/SEED-Net (បណ្តាញសាកលវិទ្យាល័យអាស៊ាន/បណ្តាញអភិវឌ្ឍន៍វិស័យអប់រំវិស្វកម្មអាស៊ីអាគ្នេយ៍)។

  ការបណ្តុះបណ្តាលវិជ្ជាជីវៈរួមទាំងការទទួលយកសិក្ខាកាមមកពីប្រទេសជិតខាងដោយរដ្ឋាភិបាល និងឧស្សាហកម្មនៅក្នុងប្រទេសឈានមុខនៅក្នុងអនុតំបន់ (ឧទាហរណ៍ប្រទេសថៃ) គួរធ្វើការពង្រឹង ចំណែកការបណ្តុះបណ្តាលពេលកំពុងបំពេញការងារនូវជំនាញនិងក្រមសីលធម៌ អាជីវកម្មដោយវិនិយោគិនបរទេសគួរយកចិត្តទុកដាក់ឲ្យបានសមស្របដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់បំផុតនៅក្នុងការអភិវឌ្ឍធនធានមនុស្ស។
- បណ្តាញបណ្តុះបណ្តាលវិជ្ជាជីវៈជាន់ខ្ពស់គួរបង្កើតឡើងដើម្បីផ្តល់ធនធានមនុស្សដែលមានជំនាញខ្ពស់ដោយប្រើប្រាស់បទពិសោធន៍ប្រទេសជប៉ុននៅក្រោមក្របខណ្ឌអាស៊ាន (បណ្តាញអប់រំវិជ្ជាជីវៈអាស៊ី)។

- <u>ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗដូចជា JICA, JETRO, មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន ADB និង ERIA សមាជិកមេគង្គ - ជប៉ុននឹងសហការគ្នាដើម្បីបង្កើត "កម្មវិធីការងារ" រួមទាំងសកម្មភាពជាក់លាក់ និងភាពទាន់ពេលវេលាសម្រាប់ការសម្រេចឲ្យបាននូវចក្ខុវិស័យអភិវឌ្ឍន៍ឧស្សាហកម្មមេគង្គ។ កម្មវិធីការងារនឹងត្រូវដាក់ជូនសម្រាប់កិច្ចពិភាក្សាឧស្សាហកម្ម</u>

រដ្ឋាភិបាលបណ្តាប្រទេសទន្លេមេគង្គ-ជប៉ុន និងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចមេគង្គ-ជប៉ុននៅក្នុងឆ្នាំ2016ខាងមុខ។ វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីការងារនឹងត្រូវរាយការណ៍ជូនកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចនៅពេលបន្ទាប់មកទៀត។